រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

សម្រាប់ការផ្សាយបន្ទាន់
ថ្ងៃ ព្រហស្បតិ៍ ទី ០៧ ខែ មេសា ឆ្នាំ ២០១១

## របាយការណ៍សំយោគទី ២៥ របស់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ

## ចំនួនកម្មករនិយោជិតក្នុងវិស័យកាត់ដេរមានការកើនឡើងវិញរហូតដល់ជាង ៣០០០០០ នាក់

ភ្នំពេញ ប្រទេសកម្ពុជា- គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO) នៅថ្ងៃនេះ ចេញផ្សាយនូវ *របាយការណ៍សំយោគទី ២៥ ស្តីពីលក្ខខណ្ឌការងារក្នុងវិស័យកាត់ដេរកម្ពុជា* ដែលធ្វើការវាយតំលៃលើការអនុលោមទៅតាមច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និងបទដ្ឋានការងារអន្តរជាតិនៅក្នុងរោងចក្រកាត់ដេរនាំចេញ។

របាយការណ៍សំយោគទី ២៥ នេះឆ្លុះបញ្ចាំងពីទិន្នន័យនៃការអនុលោមតាមច្បាប់ដកស្រង់ចេញពីរបាយការណ៍ត្រួតពិនិត្យរោងចក្រចំនួន១៣១ ដែលបានបញ្ចប់នៅចន្លោះពីថ្ងៃទី ១ ខែ ឧសភា ដល់ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១០។ របាយការណ៍នេះផ្តល់នូវព័ត៌មានជាច្រើនរួមមានព័ត៌មានអំពីទំហំរោងចក្រនៅទូទាំងវិស័យនេះ ក៏ដូចជាទិន្នន័យប្រៀបធៀបអំពីការអនុលោមតាមសិទ្ធិជាមូលដ្ឋាន និងលក្ខខណ្ឌការងារសំខាន់ៗមួយចំនួន ដើម្បីសម្រួលដល់ការតាមដាននូវកម្រិតនៃការអនុលោមតាមច្បាប់នាពេលកន្លងមក។

របាយការណ៍សំយោគទី២៥នេះ បង្ហាញពីកំណើនកំលាំងពលកម្មក្នុងវិស័យកាត់ដេរជាលើកដំបូង ចាប់តាំងពីពេលដែលវិបត្តិសេដ្ឋកិច្ចបានប៉ះពាល់ដល់ឧស្សាហកម្មនេះកាលពីចុងឆ្នាំ២០០៨។ នៅក្នុងរោងចក្រដែលត្រូវបានត្រួតពិនិត្យដោយគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ចំនួនការងារបានកើនឡើងដល់ ៣០៥៨៣២ ដោយកើនពីចំនួន ២៩៦៨០០ កាលពីឆ្នាំមុន (ពោលគឺកើនឡើងចំនួន៣%)។ ទោះបីជាចំនួនរោងចក្រមានការធ្លាក់ចុះបន្តិចបើប្រៀបធៀបជាមួយឆ្នាំមុនក៏ដោយ ប៉ុន្តែភាគរយនៃចំនួនរោងចក្រដែលមានទំហំតូច (រោងចក្រដែលមានកម្មករនិយោជិតតិចជាង ៥០០ នាក់)បានធ្លាក់ចុះ ហើយចំនួនរោងចក្រដែលមានទំហំធំមានការកើនឡើង។

ទិន្នន័យក្រសួងពាណិជ្ជកម្មបានបង្ហាញថា ចំនួនការងារបានកើនលើសពី ៣០០០០០ កាលពីខែសីហាកន្លងទៅ ដែលនេះជាការកើនឡើងជាលើកដំបូងចាប់តាំងពីខែ កុម្ភៈ ឆ្នាំ ២០០៩។ យោងតាមទិន្នន័យរបស់ក្រសួងពាណិជ្ជកម្ម ការនាំចេញសំលៀកបំពាក់សម្រាប់ឆ្នាំ ២០១០ បានកើនឡើងជិត២០% បើប្រៀបធៀបទៅនឹងឆ្នាំ២០០៩ ដែលនេះស្ទើរតែស្មើនឹងកម្រិតនៃការនាំចេញមុនមានវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨។

ជាទូទៅ កម្រិតនៃការអនុលោមទៅតាមច្បាប់នៅតែមានកម្រិតខ្ពស់ បើទោះបីជាកង្វល់លើបញ្ហាមួយចំនួននៅតែមាន ជាពិសេសទាក់ទងនឹងការ

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org/ilo

ធ្វើការបន្ថែមម៉ោង សុខភាពនិងសុវត្ថិភាពការងារ សេរីភាពក្នុងការបង្កើតអង្គការវិជ្ជាជីវៈ និងការរើសអើង ។

លទ្ធផលដែលបានរកឃើញសំខាន់ៗមួយចំនួន មានដូចតទៅ ÷

- បច្ចុប្បន្ន កម្មករនិយោជិតជាង៣ភាគ៤ កំពុងធ្វើការនៅក្នុងរោងចក្រដែលមានកម្មករចំនួន ១០០០ នាក់ ឬច្រើនជាងនេះ ប៉ុន្តែរោងចក្រភាគច្រើនមានកម្មករនិយោជិតតិចជាង ១០០០ នាក់។
- ក្នុងចំណោមរោងចក្រដែលត្រូវបានត្រួតពិនិត្យ មានរោងចក្រចំនួន ៧៣% មានសហជីពយ៉ាងហោចណាស់មួយ ពោលគឺធ្លាក់ចុះចំនួន ៦% បើធៀបនឹងរបាយការណ៍សំយោគទី២៤។
- រោងចក្រដែលបានរើសអើងចំពោះកម្មករនិយោជិត គឺមានចំនួន ៨% ពោលគឺធ្លាក់ចុះពី១៣%នៅក្នុងរបាយការណ៍មុន ហើយរោងចក្រដែលមានការរើសអើងប្រឆាំងនឹងសហជីពគឺមានចំនួន ៥%ពោលគឺកើនឡើងពី ២% ចំណែកឯរោងចក្រដែលរំខានដល់សេរីភាពរបស់កម្មករនិយោជិតក្នុងការបង្កើតអង្គការវិជ្ជាជីវៈមានចំនួន ៤% ដោយបានកើនឡើងពី ២%។
- ពុំមានកម្មករនិយោជិតក្រោមអាយុត្រូវបានរកឃើញនោះទេ។
- មានរោងចក្រចំនួន ១៣% ក្នុងចំណោមរោងចក្រទាំងឡាយដែលត្រូវបានត្រួតពិនិត្យ មានក្លូដកម្មដែលភាគរយនេះបានកើនឡើង ពី ៩% នៅក្នុងរបាយការណ៍មុន។
- ការអនុលោមទៅតាមលក្ខខណ្ឌប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតពេញសិទ្ធិ គឺមានកម្រិតខ្ពស់ចំនួន ៩៩%។ ចំណែកនៅក្នុងរោងចក្រដែលមានកម្មករនិយោជិតម្ហូងម្ហាលវិញកម្រិតនៃការអនុលោមទៅតាមច្បាប់ក្នុងការផ្តល់ប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតទាំងនោះ គឺមានកម្រិត ៨៩% ពោលគឺធ្លាក់ចុះពី៩៣% ក្នុងរបាយការណ៍មុន។
- រោងចក្រចំនួន ៩៧% បានផ្តល់ការឈប់សម្រាកប្រចាំឆ្នាំដែលមានរយៈពេល ១៨ ថ្ងៃ ដោយផ្តល់ឱ្យជាថ្ងៃឈប់សម្រាក ឬជាថវិកាជំនួស។ ការអនុលោមទៅនឹងលក្ខខណ្ឌប្រាក់ឈ្នួលសម្រាប់ការឈប់សម្រាកលំហែមាតុភាព ធ្លាក់ចុះចំនួន ១០% មកនៅត្រឹមតែ ៥៥% ខណៈពេលដែលការអនុលោមតាមលក្ខខណ្ឌនៃការឈប់សម្រាកឈឺដោយមានប្រាក់ឈ្នួល បានកើនឡើងចំនួន ១% មកត្រឹម ៧៨% បើប្រៀបធៀបជាមួយនឹងរបាយការណ៍មុន។
- រយៈពេលម៉ោងធ្វើការបានកើនឡើង ស្របពេលជាមួយនឹងការងើបឡើងវិញរបស់វិស័យនេះ ដែលជាលទ្ធផល នាំឱ្យកម្រិតនៃការអនុលោមតាមតម្រូវការនៃការធ្វើការងារបន្ថែមម៉ោងមានការធ្លាក់ចុះ។ ការអនុលោមទៅតាមច្បាប់ស្តីពីកំហិតភាពញឹកញាប់ និងរយៈពេលនៃការធ្វើការបន្ថែមម៉ោង បានធ្លាក់ចុះចំនួន ៤% និង ៨% បើប្រៀបធៀបនឹងរបាយការណ៍មុន ខណៈពេលដែលការអនុលោមតាមច្បាប់ស្តីពីការធ្វើការបន្ថែមម៉ោងដោយមានការស្ម័គ្រចិត្ត បានធ្លាក់ចុះចំនួន៣% មកនៅត្រឹម ៩០%។
- ការអនុលោមទៅតាមលក្ខខណ្ឌផ្តល់ឧបករណ៍ការពារខ្លួនដល់កម្មករនិយោជិត បានថយចុះចំនួន ៣% ចំណែកឯការអនុលោមទៅតាមលក្ខខណ្ឌតម្លើងរបាំងការពារម្ជុលលើម៉ាស៊ីនដេរ កើនឡើងចំនួន ៨%។
- ក្នុងចំណោមបញ្ហា ដែលមិនបានអនុលោមតាមច្បាប់ធំៗចំនួន ១០ មានបញ្ហាចំនួន៨ ពាក់ព័ន្ធនឹងការធ្វើការបន្ថែមម៉ោង និងសុខភាពនិងសុវត្ថិភាពការងារ ដែលនេះបានឆ្លុះបញ្ចាំងពីបញ្ហាដ៏តឹងតែង ដែលនិយោជកជួបប្រទះនៅក្នុងការដោះស្រាយនូវបញ្ហាទាំងនេះ។ តែទោះបីយ៉ាងណាក៏ដោយ ក៏មានការកែលម្អនូវលក្ខខណ្ឌមួយចំនួនដែលពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ។

របាយការណ៍សំយោគទី ២៥ ស្តីពីលក្ខខណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា មានជាភាសា**ខ្មែរ** **អង់គ្លេស** និង**ចិន** ដែលអាចរកបាននៅលើគេហទំព័រ www.betterfactories.org ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក ប៊ុន យិញ
មន្ត្រីទំនាក់ទំនងព័ត៌មាន
អ៊ីម៉ែល៖ ying@ilo.org
ទូរស័ព្ទ៖ ០១២ ៩០ ២៩ ៩០